# ម៉ូឌុល ៣

## តម្រាសម្រាប់អ្នកសម្របសម្រួល

### វគ្គបេសកកម្មពហុគុណ

ការដាំក្រុមជំនុំដែលមានសុខភាពល្អ

revised 3/4/19

# បេសកកម្មពហុគុណ
## ទិដ្ឋភាពទូទៅនៃកម្មវិធីសិក្សាអំពីការដាំក្រុមជំនុំ

| | ម៉ូឌុល ១ ការដាំក្រុមជំនុំ ដែលមានសុខភាពល្អ | ម៉ូឌុល ២ ការត្រៀមរៀបចំដើម្បី ចែកចាយដំណឹងល្អ | ម៉ូឌុល ៣ ការយល់ដឹងផែនការ របស់ព្រះ | ម៉ូឌុល ៤ ការចែកចាយ ដំណឹងល្អ | ម៉ូឌុល ៥ នាំមនុស្សឆ្ពោះ ទៅរកជំនឿ | ម៉ូឌុល ៦ ការធ្វើឲ្យសិស្ស រីកចម្រើន |
|---|---|---|---|---|---|---|
| ការចាប់ផ្ដើមជាមួយព្រះ | គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះខាងទេវសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះខាងបេសកកម្មសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះយុទ្ធសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | ការរស់នៅតាមដំណឹងល្អ | ការរីកចម្រើនរបស់គ្រិស្តបរិស័ទ: ព្រះគ្រិស្តជាចំណុចផ្ដោតអារម្មណ៍ (ឬព្រះគ្រិស្តជាចំណុចប្រសព្វ) |
| ម៉ោងទី ១ | **តើក្រុមជំនុំដែលមានសុខភាពល្អមានន័យយ៉ាងដូចម្ដេច?** | **ការធ្វើផែនទីខាងវិញ្ញាណ: គោលការណ៍នៃការស្រាវជ្រាវ** | **អ្វីដែលព្រះកំពុងតែបង្ហាញខ្ញុំ: ការចែកចាយការស្រាវជ្រាវរបស់លោកអ្នក** | **ការប្រោសឲ្យបានសុចរិតដោយសារជំនឿ** | **ឧបសគ្គរាំងរាដល់ការផ្សាយដំណឹងល្អ** | **មហាបេសកកម្ម និងការដាំក្រុមជំនុំ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | បេសកកម្ម អត្ថបទ និងបរិបទ | និមិត្ត អត្ថបទ និងបរិបទ | ត្រូវបានបញ្ជាក់នៅក្នុងការត្រាស់ហៅរបស់ព្រះ | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស |
| ម៉ោងទី ២ | **តើអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អមានន័យយ៉ាងដូចម្ដេច?** | **នេះជាអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់ខ្ញុំ! ការអភិវឌ្ឍន៍ និងការចែកចាយទីបន្ទាល់ផ្ទាល់ខ្លួន** | **អ្វីដែលព្រះកំពុងតែបង្ហាញខ្ញុំ: ការចែកចាយទីបន្ទាល់របស់លោកអ្នក និងការជ្រើសអធិស្ឋាន** | **គោលការណ៍ដឹកនាំនៅក្នុងព្រះគម្ពីរ** | **ដំណើរការនៃការប្រែចិត្ត I** | **គន្លឹះទៅរកភាពជោគជ័យក្នុងការបង្កើតសិស្ស** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | បញ្ជាក់អះអាងនៅក្នុងការត្រាស់ហៅរបស់ព្រះ | ការផ្សាយដំណឹងល្អ | និមិត្ត អត្ថបទ និងបរិបទ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការផ្សាយដំណឹងល្អ | ការបង្កើតសិស្ស |
| ម៉ោងទី ៣ | **ការគិត «អ» តើព្រះជាម្ចាស់ចង់បានអ្វី?** | **ការដឹកនាំក្រុមតូច** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការសង្កេតស្គាល់និមិត្តរបស់ព្រះ** | **ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ** | **ដំណើរការនៃការប្រែចិត្ត II** | **ស្គាល់គោលដៅរបស់លោកអ្នក ស្គាល់មនុស្សរបស់លោកអ្នក** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ ការបង្កើតសិស្ស និងការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ | ការបង្កើតសិស្ស |
| ម៉ោងទី ៤ | **រង្វង់នៃការដាំក្រុមជំនុំ** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន II: ការសង្កេតមើលព្រះបន្ទូល** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់បេសកកម្ម** | **ការចាប់ផ្ដើមក្រុមតូច** | **ការផ្សាយដំណឹងល្អក្រុមតូច** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន IV: ការអនុវត្តន៍ព្រះបន្ទូល** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស |
| ម៉ោងទី ៥ | **ហេតុអ្វីក្រុមតូច?** | **របៀបបំផុសការអធិស្ឋានសម្រាប់ក្រុមជំនុំដែលលោកអ្នកបានដាំ** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់គុណតម្លៃ** | **ការផ្សាយដំណឹងល្អ និងការបំពេញសេចក្ដីត្រូវការរបស់សហគមន៍** | **ការអនុវត្តន៍៖ បទពិសោធន៍ក្រុមតូច** | **ការយល់ដឹងអំពីគតិលោក** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការបម្រើ | ការផ្សាយដំណឹងល្អ | បញ្ជាក់អះអាងនៅក្នុងការត្រាស់ហៅរបស់ព្រះ |
| ម៉ោងទី ៦ | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន: អនុញ្ញាតឲ្យព្រះគម្ពីរបង្រៀនយើង** | **វិធានស្ដីអំពីការអធិស្ឋានទំនុកដំកើង ៩៥** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់យុទ្ធសាស្ត្រ** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន III: ការបកស្រាយព្រះបន្ទូល** | **ការធ្វើបទបង្ហាញផែនការមេ** | **វិធានស្ដីអំពីការអធិស្ឋានអរព្រះគុណដល់ព្រះសម្រាប់សេចក្ដីស្មោះត្រង់របស់ព្រះអង្គ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការថ្វាយបង្គំ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការធ្វើសំយោគគំនិត | ការថ្វាយបង្គំ |

| | ម៉ូឌុល ៧<br>ការសង់ក្រុម | ម៉ូឌុល ៨<br>ការសង់ក្រុម | ម៉ូឌុល ៩<br>ការថែទាំមនុស្ស | ម៉ូឌុល ១០<br>ការបង្កើតឲ្យមានក្រុមជំនុំ | ម៉ូឌុល ១១<br>ការរៀបចំផែនការសម្រាប់ពេលអនាគត | ម៉ូឌុល ១២<br>ឆ្ពោះទៅមុខដោយការរួបរួម |
|---|---|---|---|---|---|---|
| ការចាប់ផ្ដើមជាមួយព្រះ | ត្រូវបានបំផ្លាស់បំប្រែដោយសារដំណឹងល្អ | ព្រះគុណមានសម្រាប់អ្នកបន្ទាបខ្លួន | សេចក្ដីស្រឡាញ់ គ្រឹះនៃព័ន្ធកិច្ច | ដើម្បីឲ្យលោកិយបានជឿ យ៉ូហាន ១៧ | ការរាប់តម្លៃ | រហូតដល់លោកិយទាំងមូល! |
| ម៉ោងទី ១ | **គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំ** | **ក្រុមការងារ: ការធ្វើការយ៉ាងមានប្រសិទ្ធភាពជាមួយអ្នកដទៃ** | **ការផ្សាយដំណឹងល្អតាមរយៈទំនាក់ទំនង** | **តួនាទីរួមរបស់ក្រុមជំនុំ** | **សេចក្ដីផ្ដើមអំពីភាពជាអ្នកមើលខុសត្រូវ** | **ការដោះស្រាយជម្លោះ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការថែទាំសមាជិកក្រុមតូច | ការធ្វើសំយោគគំនិត | ភាពជាអ្នកមើលខុសត្រូវលើធនធាន | ការប្រកបគ្នា |
| ម៉ោងទី ២ | **ក្រុមជំនុំ: សរីរាង្គដែលមានជីវិត** | **ការអភិវឌ្ឍន៍ក្រុម** | **ការប្រកបគ្នា** | **ព័ន្ធកិច្ចតាមរយៈអំណោយទានខាងវិញ្ញាណ** | **ភាពជាអ្នកមើលខុសត្រូវផ្នែកហិរញ្ញវត្ថុ** | **ការប្រែចិត្តជាមាគ៌ានៃជីវិត** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការប្រកបគ្នា | ការបំផុសរូបកាយស្របទៅតាមអំណោយទានខាងវិញ្ញាណ | ភាពជាអ្នកមើលខុសត្រូវលើធនធាន | ការប្រកបគ្នា |
| ម៉ោងទី ៣ | **តើក្រុមមនុស្សក្លាយជាក្រុមជំនុំនៅពេលណា?** | **ភាពសំខាន់នៃការពិភាក្សានៅក្នុងក្រុមតូច** | **ការថែទាំសហគមន៍របស់យើង** | **របៀបប្រើការស្ទង់រកអំណោយទានខាងវិញ្ញាណ** | | **ការប្រែចិត្ត និងការស្ដារឡើងវិញ: វិន័យក្រុមជំនុំ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ អត្ថបទ និងបរិបទ | ការបំផុសរូបកាយស្របទៅតាមអំណោយទានខាងវិញ្ញាណ | | ការប្រកបគ្នា |
| ម៉ោងទី ៤ | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសនុមាន V: របៀបប្រើការសិក្សាព្រះគម្ពីរបែបវិសេសនុមាន** | **ការហ្វឹកហ្វឺនអ្នកដឹកនាំថ្មីរបស់ក្រុមតូច** | **លក្ខណៈរបស់ក្រុមជំនុំដែលរីកចម្រើន** | **ភាពសំខាន់នៃសង្គ្រាមខាងវិញ្ញាណ** | | **ការបញ្ជូនអ្នកដទៃឲ្យទៅធ្វើព័ន្ធកិច្ច** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការបង្កើតសិស្ស | ការបង្កើតសិស្ស ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការធ្វើសំយោគគំនិត | ការប្រកបគ្នា | ការជួបជុំពិភាក្សាអំពី ការរៀបចំផែនការយុទ្ធសាស្ត្រ I | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ |
| ម៉ោងទី ៥ | **ប្រវត្តិអ្នកដឹកនាំគ្រិស្តបរិស័ទ** | **របៀបទំនាក់ទំនង** | **ការដឹកនាំបែបបម្រើ** | **របៀបដឹកនាំក្រុមជំនុំនៅក្នុងការថ្វាយបង្គំ** | | **ក្រុមជំនុំរបស់យើង និងរូបកាយព្រះគ្រិស្តដែលធំជាង** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការថ្វាយបង្គំ | | ការប្រកបគ្នា |
| ម៉ោងទី ៦ | **ការអធិប្បាយតាមព្រះគម្ពីរ I: ការយល់អំពីរាជសារ** | **ការអធិប្បាយតាមព្រះគម្ពីរ II: ការយល់អំពីអ្នកស្ដាប់** | **វិធានស្ដីអំពីការអធិស្ឋាន: អេភេសូរ ៣–៥** | **ការអធិប្បាយតាមព្រះគម្ពីរ III: ការយល់អំពីខ្លួនឯង** | | **វិធានស្ដីអំពីការអធិស្ឋាន: អធិស្ឋានដើម្បីផ្សព្វផ្សាយដំណឹងល្អ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការថ្វាយបង្គំ | ការថ្វាយបង្គំ | ការប្រកបគ្នា | ការថ្វាយបង្គំ | ភាពជាអ្នកមើលខុសត្រូវលើធនធាន, ការប្រោសនិមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ |

បេសកកម្មពហុគុណ
ម៉ូឌុលការដាំក្រុមជំនុំដែលមានសុខភាពល្អ
ព័ន្ធកិច្ចបណ្ដាញពហុគុណ
ក្រុមជំនុំកាន់តែច្រើន / ក្រុមជំនុំកាន់តែរឹងមាំ
**រក្សាសិទ្ធិ © ២០១៥**

មេរៀនហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំនេះ គឺជាការរួមបញ្ចូលគ្នានៃវគ្គសិក្សាអាល់ប្រ៊ិឌ អូមេហ្គា និងមេរៀនការដាំក្រុមជំនុំដែលមានសុខភាពល្អរបស់ព័ន្ធកិច្ចបណ្ដាញពហុគុណ (MNM)។

MNM បានទទួលការអនុញ្ញាតពីមជ្ឈមណ្ឌលហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំ និងពីព័ន្ធកិច្ច World Ministries ដើម្បីបោះពុម្ពមេរៀននេះឲ្យក្រុមជំនុំប្រើ។

លោកអ្នក**ត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឲ្យបោះពុម្ព និងចែកចាយមេរៀននេះ** តាមទម្រង់ណាមួយដែល: (១) ឲ្យ តម្លៃប្រភពដើម (២) បញ្ជាក់ប្រាប់ ប្រសិនបើមានការកែសម្រួល (៣) មិនត្រូវយកថ្លៃហួសពីការចំណាយបោះពុម្ព និង (៤) មិនត្រូវថតចម្លង លើសពី ១,000 ច្បាប់។

វគ្គអូមេហ្គា:
ការហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំ

រក្សាសិទ្ធិ © 2000, 2006 United World Mission.
មេរៀននេះរក្សាសិទ្ធិដើមដោយ The Alliance for Saturation Church Planting ហើយបានរៀបចំឡើងដោយភាពជាដៃគូសហការជាមួយ Peter Deyneka Russian Ministries, Project 250។

ប្រសិនបើលោកអ្នកចង់ដាក់មេរៀននេះនៅលើអ៊ិនធើណេត ឬប្រសិនបើលោកអ្នកមានបំណងចង់ប្រើខុសពីអ្វីដែលបានរៀបរាប់ខាងលើ សូមទំនាក់ទំនង United World Mission, ATTN: Jay Weaver/Omega, 9401-B Southern Pine Blvd., Charlotte, NC 28273-5596, ឬ omega_course@alliancescp.org។

ការបកប្រែ និងការផ្លាស់ប្ដូរស្របតាមបរិបទរបស់លោកអ្នក ក៏ត្រូវបានលើកទឹកចិត្តឲ្យធ្វើផងដែរ។

យើងខ្ញុំសូមអរគុណដល់លោកបណ្ឌិត Jerry Wofford និងលោកបណ្ឌិត Jeff Hale សម្រាប់ការរួមចំណែកដ៏មានតម្លៃរបស់ពួកលោក ក្នុងការរៀបចំមេរៀននេះ។
Gary Teja and John Wagenveld បណ្ណាធិការមេរៀនបេសកកម្មពហុគុណ
**www.multiplicationnetwork.org**

| | គំរូហ្វឹកហ្វឺនសម្រាប់ម៉ូឌុល ៣ រយៈពេលមួយថ្ងៃ | |
|---|---|---|
| | សេចក្តីផ្តើមអំពីម៉ូឌុល ៣ | ៨:០០ |
| | ចាប់ផ្តើមជាមួយព្រះ_ គ្រឹះខាងបេសកកម្មសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | ៨:១៥ |
| | ការធ្វើរបាយការណ៍ | ៨:៣០ |
| ម៉ោងទីមួយ | អ្វីដែលព្រះជាម្ចាស់កំពុងបង្ហាញខ្ញុំ: ការចែកចាយអំពីការស្រាវជ្រាវរបស់លោកអ្នក | ៩:០០ |
| | សម្រាក | ១០:០០ |
| ម៉ោងទីពីរ | អ្វីដែលព្រះជាម្ចាស់កំពុងបង្ហាញខ្ញុំ: ការចែកចាយទីបន្ទាល់ និងបទពិសោធន៍នៃការដើរអធិស្ឋានរបស់លោកអ្នក | ១០:១៥ |
| ម៉ោងទីបី | ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការសង្កេតស្គាល់និមិត្តរបស់ព្រះ | ១១:១៥ |
| | អាហារថ្ងៃត្រង់ | ១២:១៥ |
| ម៉ោងទីបួន | ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់បេសកកម្ម | ១:១៥ |
| ម៉ោងទីប្រាំ | ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់គុណតម្លៃ | ២:១៥ |
| | សម្រាក | ៣:១៥ |
| ម៉ោងទីប្រាំមួយ | ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់យុទ្ធសាស្ត្រ | ៣:៣០ |
| | ការបញ្ចប់ | ៤:៣០ |
| | បិទបញ្ចប់ថ្ងៃនោះ | ៤:៤៥ |

# ការយល់ដឹងអំពីនិមិត្តរបស់ព្រះ
# ម៉ូឌុល ៣

កម្មវត្ថុមេរៀនៈ

- សិក្ខាកាមនឹងអាចពណ៌នាអំពីតួនាទី និងការខុសប្លែកគ្នារវាង (ក) សេចក្តីថ្លែងការណ៍និមិត្ត (ខ) សេចក្តីថ្លែងការណ៍បេសកកម្ម (គ) សេចក្តីថ្លែងការណ៍គុណតម្លៃស្នូល និង (ឃ) យុទ្ធសាស្រ្តដាំក្រុមជំនុំ។
- សិក្ខាកាមនឹងចាប់ផ្តើមបង្កើតសេចក្តីថ្លែងការណ៍និមិត្ត សេចក្តីថ្លែងការណ៍បេសកកម្ម សេចក្តីថ្លែងការណ៍គុណតម្លៃស្នូល និងយុទ្ធសាស្រ្តដាំក្រុមជំនុំដែលពាក់ព័ន្ធនឹងការចាប់ផ្តើមក្រុមជំនុំថ្មីរបស់ពួកគេ។
- ដោយប្រើ«ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៤» សិក្ខាកាមនឹងកែសម្រួលឡើងវិញនិមិត្ត បេសកកម្ម គុណតម្លៃស្នូល និងយុទ្ធសាស្រ្ត ជាមួយគ្រូគង្វាល អ្នកដឹកនាំដែលទ្រទ្រង់ក្រុមជំនុំ និងអ្នកដទៃទៀតដែលពាក់ព័ន្ធនៅក្នុងក្រុមជំនុំដែលបានដាំ (តាមដែលស័ក្តិសម)។

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ទោះបីជា «ម៉ោងទី ៥: ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: គុណតម្លៃ» មានរយៈពេលមួយម៉ោងពេញនៅក្នុងកាលវិភាគសម្រាប់ម៉ូឌុលនេះក៏ដោយ ម៉ោងនោះត្រូវការពេលវេលាប្រហែលតែ ៣០ នាទីប៉ុណ្ណោះ។ ផ្នែកចម្បងនៃកិច្ចការនេះនឹងបានបានសម្រេចនៅក្នុងផែនការសកម្មភាពរបស់អ្នកដាំក្រុមជំនុំសម្រាប់ម៉ូឌុល ៤។ លោកអ្នកអាចប្រើពេលនៅសល់តាមដែលត្រូវការ ឧទាហរណ៍ សម្រាប់រំឭកមេរៀនចាស់ ការបង្រៀនកាលពីមុន ការអធិស្ឋានជាក្រុមតូច ការឆ្លើយសំណួរ និងបញ្ហាប្រឈមដែលសិក្ខាកាមមាន ឬអាចសម្រាកមុនម៉ោងក៏បាន។

សេចក្តីផ្តើមអំពីម៉ូឌុល ៣

ការណែនាំសម្រាប់អ្នកសម្របសម្រួល (២ នាទី)

- ស្វាគមន៍សិក្ខាកាមដោយភាពកក់ក្តៅ រាក់ទាក់ និងភាពសាទរ។
- នាំមុខសិក្ខាកាមអធិស្ឋានខ្លីជាមួយគ្នា ថ្វាយថ្ងៃនោះសម្រាប់ជាសិរីល្អដល់ព្រះ។

សកម្មភាពល្បែងកម្សាន្តៈ ការណែនាំ (៥ នាទី)

ចូរប្រាប់មនុស្សគ្រប់គ្នានៅក្នុងក្រុមត្រូវថា ពួកគេមានពេល ២ នាទីដើម្បីគិតរកសំណួរមួយ ហើយសួរសំណួរនោះទៅមនុស្សដទៃទៀតនៅក្នុងក្រុម។ សំណួរកាន់តែល្អ លោកអ្នកនឹងទទួលបានចម្លើយដែលកាន់តែមានលក្ខណៈផ្ទៃប្រឌិត និងគួរឲ្យចាប់អារម្មណ៍។ ក្រោយពីគ្រប់គ្នាបានគិតឃើញសំណួររួចហើយ ចូរអញ្ជើញពួកគេឲ្យក្រោកឈរឡើង រួច សួរសំណួររបស់ខ្លួនដល់មនុស្សឲ្យបានច្រើនតាមដែលអាចធ្វើនៅក្នុងរយៈពេល ២ នាទី។ ចូរសរសេរឈ្មោះ និងចម្លើយរបស់មនុស្សម្នាក់ៗ។ ពីរនាទីក្រោយ ចូរឲ្យក្រុមអង្គុយចុះវិញ ហើយអញ្ជើញមនុស្សឲ្យចែកចាយការមួយចំនួនដែលពួកគេបានដឹងអំពីគ្នាទៅវិញទៅមក។

សេចក្តីផ្តើមអំពីនិមិត្ត បេសកកម្ម គុណតម្លៃ និងយុទ្ធសាស្រ្ត (៨ នាទី)

- នៅលើក្តារខៀន ឬផ្ទាំងក្រដាសធំបិតជាប់លើជញ្ជាំង ចូរសរសេរពាក្យទាំងនេះៈ និមិត្ត បេសកកម្ម គុណតម្លៃ និងយុទ្ធសាស្រ្ត។
- ចូរសួរសំណួរទាំងនេះទៅកាន់ក្រុមៈ
  ១) តើលោកអ្នកឲ្យនិយមន័យគោលគំនិតទាំងនេះយ៉ាងដូចម្តេច?
  ២) តើគោលគំនិតទាំងនេះខុសពីគ្នាយ៉ាងដូចម្តេច?
  ៣) តើនិមិត្ត បេសកកម្ម គុណតម្លៃ និងយុទ្ធសាស្រ្តពាក់ព័ន្ធអ្វីជាមួយនឹងការដាំក្រុមជំនុំ?
- ចូរនិយាយថាៈ «ថ្ងៃនេះ យើងនឹងស្វែងយល់ជាមួយគ្នាអំពីសារៈសំខាន់របស់និមិត្ត បេសកកម្ម គុណតម្លៃ និងយុទ្ធសាស្រ្តសម្រាប់ការដាំក្រុមជំនុំ។ គោលគំនិតទាំងនេះគឺជាវិធីអនុវត្តជាក់ស្តែងដែលក្រុមជំនុំបង្ហាញចេញថាក្រុមជំនុំជានរណា និងមូលហេតុដែលក្រុមជំនុំធ្វើអ្វីដែលក្រុមជំនុំធ្វើ។ សរុបមក គោលគំនិតទាំងនេះពណ៌នាលក្ខណៈរបស់ក្រុមជំនុំ និងបេសកកម្មរបស់ក្រុមជំនុំ។ នៅពេលដែលយើងកំពុងដាំក្រុមជំនុំ យើងកំពុងអនុវត្តគោលការណ៍ដែលពាក់ព័ន្ធបេសកកម្ម ដូច្នេះយើងនឹងចាប់ផ្តើមការស្វែង

យល់របស់យើងអំពីនិមិត្ត បេសកកម្ម គុណតម្លៃ និងយុទ្ធសាស្ត្រ ជាមួយនឹងការចាប់ផ្ដើមជាមួយព្រះដែលផ្ដោតលើគ្រឹះខាងបេសកកម្មនៅក្នុងការដាំក្រុមជំនុំដែលមានសុខភាពល្អ»។

# ចាប់ផ្តើមជាមួយព្រះ
# គ្រឹះខាងបេសកកម្មសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ (១៥ នាទី)

សកម្មភាពបើក (២ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ចូរសុំសិក្ខាកាមឲ្យចែកចាយគំនិតរបស់ពួកគេអំពីមូលហេតុសម្រាប់ដាំក្រុមជំនុំថ្មី។ ចូរសុំពួកគេឲ្យស្តាប់ដើម្បីមើលថាតើហេតុផលណាមួយក្នុងចំណោមហេតុផលទាំងនេះត្រូវបានលើកឡើងនៅក្នុងម៉ោងនេះ។

ការសិក្សាព្រះគម្ពីរ (១៣ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ចូរសុំអ្នកស្ម័គ្រចិត្តឲ្យអានឮៗបទគម្ពីរសម្រាប់គ្រឹះខាងទេវសាស្ត្រនីមួយៗសម្រាប់បេសកកម្មរបស់ក្រុមជំនុំ។ ចូរដឹកនាំក្រុមរកឲ្យឃើញគោលការណ៍បេសកកម្មនីមួយៗចេញពីបទគម្ពីរដែលបានអាន និងបំពេញឲ្យត្រូវតាមកន្លែងនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

គោលការណ៍ទី ១ | អ្វីដែលក្រុមជំនុំគឺជា (សូល/លក្ខណៈរបស់ក្រុមជំនុំ)

អានៈ ១ ពេត្រុស ២:៩-១២ អេភេសូរ ៤:២៤, ១ កូរិនថូស ១២:១២-១៣

សួរ សិក្ខាកាមពីអ្វីដែលយើងរៀនបានអំពីក្រុមជំនុំ / ប្រជារាស្ត្ររបស់ព្រះចេញពីបទគម្ពីរទាំងនេះ។

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ចូរសួរសិក្ខាកាមពីអ្វីដែលយើងរៀនបានអំពីក្រុមជំនុំ / ប្រជារាស្ត្ររបស់ព្រះចេញពីបទគម្ពីរទាំងនេះ។
ចូរនិយាយថាៈ «ក្រុមជំនុំជាសហគមន៍ដែលព្រះជាម្ចាស់បានបង្កើតឡើងដើម្បីធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គ ក៏ជាភ្នាក់ងារបំផ្លាស់បំប្រែនៅក្នុងសហគមន៍ និងនៅក្នុងរបស់សព្វសារពើផងដែរ»។

ក្រុមជំនុំគឺជាសហគមន៍ថ្មីដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះគ្រិស្តយេស៊ូស្រឡាញ់ ដើម្បីបានដូចព្រះជាម្ចាស់ក្នុងសេចក្តីសុចរិត និងក្នុងសេចក្តីបរិសុទ្ធរបស់សេចក្តីពិត។ ក្រុមជំនុំគឺជារូបកាយរបស់ព្រះគ្រិស្ត ដែលបានរួមចូលគ្នាទៅជាគ្រួសារតែមួយដោយសារព្រះវិញ្ញាណរបស់ព្រះអង្គ។

គោលការណ៍ទី ២ | អ្វីដែលក្រុមជំនុំធ្វើ (តួនាទី/គោលបំណងរបស់ក្រុមជំនុំ)

អានៈ កិច្ចការ ៦:១-៧ កិច្ចការ ១១:១៩-២៦ និង ១២:២៥

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ចូរសួរថាៈ «តើក្រុមជំនុំកំពុងធ្វើអ្វីនៅក្នុងអត្ថបទគម្ពីរទាំងនេះ?»

អ្វីដែលក្រុមជំនុំធ្វើគឺផ្អែកលើក្រុមជំនុំគឺជានរណា។

គឺជា សូល លក្ខណៈ សហគមន៍ បានដូច រូបកាយរបស់ព្រះគ្រិស្ត ធ្វើ តួនាទី គោលបំណង
ចូរនិយាយថាៈ «ក្រុមជំនុំប្រកាសអំពីព្រះរាជ្យរបស់ព្រះនៅក្នុងព្រះយេស៊ូស្រឡាញ់គ្រិស្ត តំណាងឲ្យដំណឹងល្អនៅក្នុងបរិបទរបស់ខ្លួន និងចូលរួមនៅក្នុងបេសកកម្មរបស់ព្រះ។ នៅត្រង់នេះ យើងមើលឃើញថា ការស្អាងគ្រិស្តបរិស័ទទៅជាមួយគ្នានឹងតួនាទីរបស់ក្រុមជំនុំនៅក្នុងការប្រកាស ការបម្រើ និងការធ្វើព័ន្ធកិច្ច។ អត្ថបទគម្ពីរទាំងនេះរំឭកយើងថា ក្រុមជំនុំគឺជាប្រជារាស្ត្ររបស់ព្រះដែលមានបេសកកម្ម។ ក្រុមជំនុំធ្វើស្របទៅតាមអ្វីដែលក្រុមជំនុំគឺជា។ ដូចដែលផ្លែព្រុសដោយព្រោះវាជាផ្លែជាយ៉ាងណា ក្រុមជំនុំធ្វើបេសកកម្មដោយព្រោះក្រុមជំនុំគឺជាក្រុមជំនុំជាយ៉ាងនោះដែរ»។

គោលការណ៍ទី ៣ | ក្រុមជំនុំរៀបចំអ្វីដែលក្រុមជំនុំធ្វើ (រចនាសម្ព័ន្ធ/សណ្តាប់ធ្នាប់របស់ក្រុមជំនុំ)

ចូរអាន កិច្ចការ ៦:១-៤

ចូរសួរ អំពីរបៀបដែលពួកសិស្សបានសម្រេចចិត្តរៀបចំការងារ។

ចូរនិយាយថាៈ «ចុងក្រោយ ក្រុមជំនុំរៀបចំ និងបង្កើតរចនាសម្ព័ន្ធខ្លួន ស្របទៅតាមបរិបទ និងយុទ្ធសាស្ត្រធ្វើការរបស់ខ្លួន។ ក្រុមជំនុំផ្តល់ទម្រង់ឲ្យតួនាទីរបស់ខ្លួន ដើម្បីសម្រេចកិច្ចការដែលបាន

ប្រគល់មកឲ្យខ្លួនធ្វើ។ ដោយមានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ក្រុមជំនុំរៀបចំផែនការ អនុវត្ត វាយតម្លៃ និងផ្លាស់ប្តូរ ដើម្បីសម្រេចបេសកកម្មរបស់ខ្លួន។ គោលការណ៍គន្លឹះនៅត្រង់នេះគឺថា នៅពេលដែលក្រុមជំនុំយល់អំពីលក្ខណៈ និងគោលបំណងរបស់ខ្លួន ក្រុមជំនុំនឹងរៀបចំរចនាសម្ព័ន្ធរបស់ខ្លួនដើម្បីសម្រេចបេសកកម្មរបស់ខ្លួន»។

ក្រុមជំនុំរៀបចំ និងបង្កើតរចនាសម្ព័ន្ធខ្លួន ស្របទៅតាមបរិបទ និងយុទ្ធសាស្ត្រធ្វើការរបស់ខ្លួនដើម្បីសម្រេចគោលបំណងរបស់ខ្លួន។

ការរាយការណ៍ (៣០ នាទី)

ការណែនាំ:

- ដោយប្រើទម្រង់របាយការណ៍ខាងក្រោម ចូរដឹកនាំសិក្ខាកាមចែកចាយសកម្មភាពដាំក្រុមជំនុំរបស់ពួកគេចាប់តាំងពីបញ្ចប់ម៉ូឌុល ២ មក។
- ចូរអបអរនឹងជ័យជម្នះ ហើយលើកទឹកចិត្តអ្នកដែលបាក់ទឹកចិត្ត។ តាមពេលវេលាដែលមាន លោកអ្នកប្រហែលជាចង់ចំណាយពេលអធិស្ឋានឲ្យគ្នាទៅវិញទៅមកនៅក្នុងក្រុមតូចអំពីបទពិសោធន៍ដាំក្រុមជំនុំទាំងនេះ។
- ចូរឆ្លើយសំណួរណាមួយអំពីដំណើរការរាយការណ៍។

ធ្វើ – នរណា – គឺជា – ធ្វើ – បង្កើតរចនាសម្ព័ន្ធ – សណ្តាប់ធ្នាប់ – រៀបចំ – បង្កើតរចនាសម្ព័ន្ធ

# របាយការណ៍ដាំក្រុមជំនុំកខគ

របាយការណ៍ប្រចាំខែ

## ព័ត៌មានទូទៅ

| | | | | |
|---|---|---|---|---|
| របាយការណ៍ខែ | | បានជួបប្រជុំជាមួយគ្រូឧបជ្ឈា | បាទ/ចាស | ទេ |

| | |
|---|---|
| ឈ្មោះអ្នកដាំក្រុមជំនុំ | |
| តំបន់របស់អ្នកដាំក្រុមជំនុំ | |
| អ្នកសម្របសម្រួលតំបន់ | |

## បុគ្គល

| | គោលដៅប្រចាំខែ | លទ្ធផលប្រចាំខែ |
|---|---|---|
| អ្នកថ្មីដែលត្រូវទាក់ទង<br>អ្នកដែលត្រូវបានទាក់ទងនៅក្នុងបរិបទដាំក្រុមជំនុំ ដើម្បីប្រាប់ដំណឹងល្អ | | |
| ការប្រែចិត្តថ្មី<br>អ្នកដើរតាមព្រះយេស៊ូ | | |
| អ្នកថ្មីដែលបានទទួលបុណ្យជ្រមុជទឹក<br>អ្នកដែលបានទទួលពិធីបុណ្យជ្រមុជទឹក | | |
| អ្នកដឹកនាំថ្មីដែលកំពុងទទួលការហ្វឹកហ្វឺន<br>អ្នកដែលអ្នកដាំក្រុមជំនុំកំពុងហ្វឹកហ្វឺនឲ្យធ្វើជាអ្នកដឹកនាំ | | |

## ក្រុមតូចៈ ជាអប្បបរិមា សិស្សថ្មីពីរនាក់ និងអ្នកដឹកនាំម្នាក់

| | គោលដៅប្រចាំខែ | លទ្ធផលប្រចាំខែ |
|---|---|---|
| ក្រុមតូចថ្មី<br>ក្រុមដែលបានចាប់ផ្តើមខែនេះ | | |
| អ្នកចូលរួមថ្មីនៅក្នុងក្រុមតូច<br>មនុស្សថ្មីដែលចូលរួមក្រុមតូចនៅខែនេះ | | |
| អ្នកដឹកនាំថ្មីដែលមានមួយក្រុម<br>អ្នកដឹកនាំថ្មីដែលមានមួយក្រុមនៅក្រោមការត្រួតពិនិត្យមើលរបស់អ្នកដាំពួកជំនុំ | | |

## សំណូមពរអធិស្ឋាន (តម្រូវឲ្យសរសេរយ៉ាងតិចពេញមួយប្រឡោះនេះ)

## ទីបន្ទាល់

ព័ន្ធកិច្ចបណ្តាញពហុគុណ | កខគ របស់អ្នកដាំក្រុមជំនុំ

## ម៉ោងទី ១
## អ្វីដែលព្រះជាម្ចាស់កំពុងបង្ហាញខ្ញុំ: ការចែកចាយអំពីការស្រាវជ្រាវរបស់លោកអ្នក (៦០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ចូរនិយាយថា៖ «នៅក្នុងម៉ូឌុល ១ លោកអ្នកត្រូវបានប្រាប់ឲ្យធ្វើផែនការសកម្មភាពសម្រាប់ម៉ូឌុល ៤: ផែនការ«អ»របស់លោកអ្នក។ នៅក្នុងម៉ូឌុល ២ លោកអ្នកត្រូវបានប្រាប់ឲ្យស៊ើបអង្កេតតំបន់ដែលលោកអ្នកកំពុងមានគម្រោងដាំក្រុមជំនុំ។ សំណួរទាំងបីនៅក្នុងលំហាត់នេះបានផ្តល់ឲ្យលោកអ្នកនូវដំណើរការមួយសម្រាប់ចាប់ផ្តើមធ្វើការស្រាវជ្រាវជាមូលដ្ឋានគ្រឹះមួយចំនួន។ មុនពេលដែលយើងចូលកាន់តែជ្រៅទៅក្នុងប្រធានបទស្រាវជ្រាវ សូមយកពេលខ្លះដើម្បីរាយការណ៍គំឃើញរបស់លោកអ្នកចេញពីលំហាត់នេះ»។

- ចូរបែងចែកជាក្រុមដែលមានគ្នា ៣ នាក់ ហើយឲ្យពេលម្នាក់ៗ ១៥ នាទី ដើម្បីចែកចាយលទ្ធផលលំហាត់របស់ពួកគេ ដោយប្រើទម្រង់ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៣ មកពីក្នុងម៉ូឌុល ២។ ទម្រង់នេះត្រូវបានបង្កើតឡើងវិញនៅខាងក្រោមសម្រាប់ជួយឲ្យមានភាពងាយស្រួល។
- ចូរដើរតាមក្រុមនីមួយៗ ដើម្បីសង្កេតមើលសកម្មភាពរបស់ពួកគេ។
- បើសិនមានអ្នកមិនបានធ្វើលំហាត់នេះ ចូររកពេលនិយាយជាមួយគេផ្ទាល់ខ្លួននៅក្នុងពេលសម្រាក។ ចូរសួរពួកគេពីផែនការធ្វើលំហាត់នេះឲ្យចប់សព្វគ្រប់ មុនការហ្វឹកហ្វឺនលើកក្រោយទៀត។
- ចូរប្រើរយៈពេល ១៥ នាទីចុងក្រោយនៅក្នុងម៉ោងនេះ ដើម្បីពន្យល់អំពីលំហាត់នោះប្រាប់ក្រុមធំដោយសង្ខេប។

របាយការណ៍របស់សិក្ខាកាមម្នាក់ៗគួរតែមានរយៈពេលប្រហែល ១០-១៥ នាទី និងមានព័ត៌មានខាងក្រោមៈ

១. ផ្នែកទីមួយ—ព័ត៌មានមូលដ្ឋានគ្រឹះដែលប្រមូលបាន (៥-៧ នាទី)
ពណ៌នាតំបន់គោលដៅរបស់លោកអ្នក

- តើលោកអ្នកប្រមូលបានព័ត៌មានយ៉ាងដូចម្តេច (ការស្ទង់មតិ ការសម្ភាសក្រៅផ្លូវការ ការសង្កេតមើល/ការធ្វើផែនទី ការស្រាវជ្រាវនៅក្នុងបណ្ណាល័យ។ល។)?
- ចូរពិភាក្សាអំពីបញ្ហា ឬការលំបាកសំខាន់ៗដែលបានជួបប្រទះ និងរបៀបដែលបានយកឈ្នះការលំបាកទាំងនោះ។ លើកក្រោយទៀត តើលោកអ្នកនឹងធ្វើអ្វីខុសពីមុន?

២. ផ្នែកទីពីរ—ការវិភាគព័ត៌មានដែលបានមកពីការស្រាវជ្រាវ (៥-៨ នាទី)
ផ្នែកដែលនៅសល់នៅក្នុងបទបង្ហាញគួរតែផ្តោតលើលទ្ធផលនៃការស្រាវជ្រាវរបស់លោកអ្នក។ បទបង្ហាញគួរតែឆ្លើយសំណួរគន្លឹះខាងក្រោមៈ

- តើអ្វីជាព័ត៌មានដ៏គួរឲ្យចាប់អារម្មណ៍បំផុតដែលលោកអ្នកបានដឹងអំពីតំបន់គោលដៅរបស់លោកអ្នក និងប្រជាជនដែលកំពុងរស់នៅទីនោះ?
- តើមានព័ត៌មានដែលបានធ្វើឲ្យលោកអ្នកភ្ញាក់ផ្អើលដែរឬទេ?
- តើលោកអ្នករៀនបានការជាក់លាក់អ្វីខ្លះ ដែលជួយលោកអ្នកនៅក្នុងការកំណត់ផែនការរបស់លោកអ្នកសម្រាប់ការដាំក្រុមជំនុំនៅក្នុងតំបន់គោលដៅរបស់លោកអ្នក?
- តើលោកអ្នកបានបញ្ជាក់ការពិតដ៏សំខាន់មួយសម្រាប់ការដាំក្រុមជំនុំដែលលោកអ្នកបានដឹងរួចហើយអំពីវាលស្រែនោះ តើគឺជាការពិតអ្វី?
- តើលោកអ្នកបានរកឃើញអ្វីថ្មីអំពីវាលស្រែដែលលោកអ្នកមិនបានដឹងពីមុនមក ហើយមានសារៈសំខាន់សម្រាប់ការដាំក្រុមជំនុំ?
- តើលោកអ្នកបានរកឃើញឱកាសអ្វីខ្លះជាទ្វារដែលបើកចំហសម្រាប់ដំណឹងល្អ?
- តើលោកអ្នកបានជួបប្រទះឧបសគ្គអ្វីខ្លះ ហើយឧបសគ្គទាំងនោះអាចយកឈ្នះបានយ៉ាងដូចម្តេច?
- តើលោកអ្នកត្រូវធ្វើការស្រាវជ្រាវអ្វីថែមទៀត ដើម្បីអភិវឌ្ឍផែនការផ្សាយដំណឹងល្អ និងដាំក្រុមជំនុំដែលមានលក្ខណៈទូលំទូលាយសម្រាប់តំបន់គោលដៅរបស់លោកអ្នក?

## ម៉ោងទី ២
## អ្វីដែលព្រះជាម្ចាស់កំពុងបង្ហាញខ្ញុំ: ការចែកចាយទីបន្ទាល់របស់លោកអ្នក និងបទពិសោធន៍នៃការដើរអធិស្ឋាន (៦០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ នេះគឺជារបាយការណ៍អំពីផែនការសកម្មភាពសម្រាប់ម៉ូឌុល ៣ អំពីការធ្វើទីបន្ទាល់ និងការដើរអធិស្ឋាន ដែលមកពីម៉ូឌុល ២។

- ចូរចែកសិក្ខាកាមទៅជាក្រុមដែលមានគ្នា ៣ នាក់។
- ចូរឲ្យម្នាក់ៗចែកចាយទីបន្ទាល់ផ្ទាល់ខ្លួនដែលបានកែសម្រួលរួចហើយ និងបានចែកចាយជាសាធារណៈចាប់តាំងពីការហ្វឹកហ្វឺនលើកមុនមក។
- នៅក្នុងក្រុមតូច ចូរឲ្យម្នាក់ៗចែកចាយបទពិសោធន៍របស់គេអំពីការប្រាប់ទីបន្ទាល់ផ្ទាល់ខ្លួនដល់មនុស្ស និងការដើរអធិស្ឋាននៅក្នុងតំបន់គោលដៅរបស់គេ។
- ចូរដើរតាមក្រុមនីមួយៗដើម្បីសង្កេតមើលការពិភាក្សារបស់ពួកគេ។
- បើសិនមានអ្នកមិនបានធ្វើលំហាត់នេះ ចូររកពេលនិយាយជាមួយគេផ្ទាល់ខ្លួននៅក្នុងពេលសម្រាក។ ចូរសួរពួកគេពីផែនការធ្វើលំហាត់នេះឲ្យចប់សព្វគ្រប់ មុនការហ្វឹកហ្វឺនលើកក្រោយទៀត។
- ចូរប្រើរយៈពេល ១៥ នាទីចុងក្រោយនៅក្នុងម៉ោងនេះ ដើម្បីពន្យល់អំពីលំហាត់នោះប្រាប់ក្រុមធំដោយសង្ខេប។

# ម៉ោងទី ៣
# ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: និមិត្ត (៦០ នាទី)

## របៀបរៀបចំសេចក្តីថ្លែងការណ៍និមិត្ត

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរប្រើមេរៀនខាងក្រោម ដើម្បីណែនាំគោលគំនិតដ៏ជាសេចក្តីថ្លែងការណ៍និមិត្ត។ ចូរដឹកនាំក្រុមនៅក្នុងការបំពេញសកម្មភាពដែលមានដូចខាងក្រោម។

សេចក្តីថ្លែងការណ៍និមិត្ត គឺជាការពណ៌នាដ៏ច្បាស់លាស់ និងដ៏សាមញ្ញអំពីអ្វីដែលលោកអ្នកជឿថា ព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំធ្វើជាអ្វី។ សេចក្តីថ្លែងការណ៍និមិត្ត គួរតែបង្ហាញប្រាប់រូបភាពទាំងមូលអំពីក្រុមជំនុំរបស់លោកអ្នកស្ថិតនៅក្នុងសភាពដ៏ប្រសើរបំផុត ប៉ុន្តែជាក់លាក់ល្មមនឹងឲ្យមនុស្សផ្តោតលើសកម្មភាពច្បាស់លាស់។ សេចក្តីថ្លែងការណ៍និមិត្ត ក៏ពណ៌នាអំពីសភាពមួយដែលលោកអ្នកខំប្រឹងប្រែងឆ្ពោះទៅរក មិនមែនគ្រាន់តែជាសភាពមួយដែលបានសម្រេចរួចហើយទេ។

ដើម្បីឲ្យពាក់ព័ន្ធនឹងតំបន់គោលដៅរបស់លោកអ្នក សេចក្តីថ្លែងការណ៍និមិត្តរបស់លោកអ្នក គួរតែឆ្លុះបញ្ចាំងឲ្យឃើញអ្វីដែលលោកអ្នករៀនបាននៅក្នុងការស្រាវជ្រាវរបស់លោកអ្នក។

ឧទាហរណ៍បួនអំពីសេចក្តីថ្លែងការណ៍និមិត្ត (១៥ នាទី)

I. «យើងនឹងធ្វើជាក្រុមជំនុំដែលពេញដោយព្រះវិញ្ញាណបរិសុទ្ធ ដែលដូចជាព្រះគ្រិស្តកាន់តែខ្លាំងឡើងៗ»។
II. «យើងនឹងធ្វើជាពន្លឺរបស់ព្រះគ្រិស្តនៅក្នុងភាពងងឹតរបស់សហគមន៍យើង»។
III. «យើងនឹងធ្វើជាសហគមន៍ដែលមានជំនឿ ហើយចែងចាំងសេចក្តីសុចរិត និងសេចក្តីសង្ឃឹមរបស់ព្រះគ្រិស្តនៅក្នុងក្រុមជំនុំ និងទីក្រុងរបស់យើង ព្រមទាំងកន្លែងដទៃទៀតនៅក្នុងពិភពលោក»។
IV. «យើងនឹងធ្វើជាសហគមន៍ដ៏សុចរិត និងដ៏ស្មោះត្រង់ ដោយបម្រើមនុស្សបាត់បង់ និងបងប្អូនរួមជំនឿនៅក្នុងសហគមន៍ និងតំបន់របស់យើង ព្រមទាំងនៅជុំវិញពិភពលោក»។

សូមកត់សម្គាល់ថា សេចក្តីថ្លែងការណ៍និមិត្តនីមួយៗ សុទ្ធតែឆ្លុះបញ្ចាំងឲ្យឃើញពីអ្វីដែលព្រះជាម្ចាស់បានបង្រៀនយើងនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គអំពីការដែលក្រុមជំនុំគួរតែដូចជាអ្វីនោះ។ ទោះបីយ៉ាងណាក៏ដោយ សេចក្តីថ្លែងការណ៍ទាំងនេះមិនមានប្រសិទ្ធភាពស្មើគ្នាទេក្នុងនាមជាសេចក្តីថ្លែងការណ៍និមិត្ត។

I. សេចក្តីថ្លែងការណ៍ទីមួយ ពណ៌នាអំពីស្ថានភាពមួយដែលអាចពិតខ្លះៗនៅពេលឥឡូវនេះ ហើយរំពឹងទុកថាយូរទៅនឹងបានប្រសើរឡើង។ សេចក្តីថ្លែងការណ៍នេះមិនមានលក្ខណៈជាក់លាក់របស់ក្រុមជំនុំ ឬសកម្មភាពព័ន្ធកិច្ចដែលត្រូវខំប្រឹងប្រែងឆ្ពោះទៅរកទេ។

ការពណ៌នា ព្រះជាម្ចាស់ រូបភាព ឆ្ពោះទៅរក
II. សេចក្តីថ្លែងការណ៍ទីពីរ កាន់តែស្រពិចស្រពិល ហើយអាចពិតនៅពេលណាមួយតាមរបៀបផ្សេងៗ។ម្តងទៀតមិនមានការលើកឡើងអំពីលក្ខណៈ ឬសកម្មភាពព័ន្ធកិច្ចកម្រិតណាមួយទេ។

III. សេចក្តីថ្លែងការណ៍ទីបី ពេញលេញច្រើន ពីព្រោះសេចក្តីថ្លែងការណ៍នេះ ពណ៌នាអំពីលក្ខណៈរបស់ក្រុមជំនុំ (សេចក្តីសុចរិត និងសេចក្តីសង្ឃឹមនៅក្នុងព្រះគ្រិស្ត) និងកន្លែងដែលពួកគេនឹងធ្វើព័ន្ធកិច្ច (ក្រុមជំនុំ ទីក្រុង និងកន្លែងដទៃទៀតនៅលើពិភពលោក)។ ទាំងលក្ខណៈ ទាំងវិសាលភាពរបស់ព័ន្ធកិច្ចគឺជាកត្តាដែលត្រូវប្រឹងប្រែងឆ្ពោះទៅរក។

IV. សេចក្តីថ្លែងការណ៍ទីបួន ពេញលេញបំផុត។ សេចក្តីថ្លែងការណ៍នេះបង្ហាញប្រាប់លក្ខណៈរបស់ក្រុមជំនុំ អ្នកដែលនឹងទទួលបានប្រយោជន៍ពីព័ន្ធកិច្ច និងវិសាលភាពរបស់ព័ន្ធកិច្ច។ ឧត្តមគំនិតទាំងនេះបានប្រាប់យ៉ាងច្បាស់ ហើយខ្លឹមសារក៏ស្របតាមព្រះគម្ពីរដែរ។

សកម្មភាពផ្សេងៗ (៤៥ នាទី)

១. នៅក្នុងក្រុមតូច ឬជាគូ ចូរកត់ត្រាពាក្យមួយៗឲ្យបានច្រើនដែលពណ៌នាអំពីក្រុមជំនុំថ្មីរបស់លោកអ្នក

ហាក់បីដូចជាមានរួចហើយ ស្របទៅតាមគោលការណ៍នៅក្នុងព្រះគម្ពីរ—របៀបដែលលោកអ្នកជឿថា ព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំក្លាយជាអ្វី! ពាក្យខ្លះ អាចមានដូចជា: សុចរិត ស្មោះត្រង់ ស្រឡាញ់ អំណរ មេត្តា សប្បុរស។ល។ ពាក្យទាំងនេះពណ៌នាអំពីលក្ខណៈរបស់ក្រុមជំនុំ។ ចូរកត់ត្រាពាក្យពណ៌នាទាំងនេះ ដោយប្រើពាក្យនីមួយៗ ដើម្បីបញ្ចប់ប្រយោគ:

ព្រះជាម្ចាស់ចង់ឲ្យយើងក្លាយជា...

___

___

២. បន្ទាប់មកទៀត ចូរកត់ត្រាអ្នកដែលលោកអ្នកជឿថា លោកអ្នកត្រូវបម្រើ ដោយបញ្ចប់ប្រយោគនេះ

ព្រះជាម្ចាស់ចង់ឲ្យយើងបម្រើ ...(អ្នកណា?)

___

___

៣. ជាចុងក្រោយ កត់ត្រាសកម្មភាពជាច្រើនដែលក្រុមជំនុំថ្មីរបស់លោកអ្នកនឹងធ្វើ នៅពេលដែលក្រុមជំនុំនោះមានស្ថានភាពដ៏ប្រសើរ។ ទាំងនេះអាចជាឃ្លាខ្លះៗ។ ឧទាហរណ៍មួយចំនួនមាន:

- នាំយកដំណឹងល្អទៅដល់ពិភពលោក
- បម្រើមនុស្សគ្រប់វ័យនៅក្នុងសហគមន៍របស់យើង
- ឲ្យសមាជិកទាំងអស់ចូលរួមនៅក្នុងការបង្កើតសិស្សខាងវិញ្ញាណ
- រីកចម្រើនឡើងជាទៀងទាត់ខាងហិរញ្ញវត្ថុ

លោកអ្នកអាចកត់ត្រាសកម្មភាពទាំងនេះ ដោយបញ្ចប់ប្រយោគនេះ:

៤. យើងនឹងបង្ហាញចេញអត្តចរិតរបស់យើងតាមរយៈ ...

___

___

___

៥. ឥឡូវនេះ ចូរពិភាក្សាជាមួយដៃគូ ឬក្រុមតូចរបស់លោកអ្នកអំពីពាក្យដែលលោកអ្នកបានជ្រើសរើសដើម្បីពណ៌នាលក្ខណៈដ៏ប្រសើររបស់ក្រុមជំនុំ មនុស្សដែលក្រុមជំនុំនឹងបម្រើ និងឃ្លាដែលបង្ហាញប្រាប់សកម្មភាពដ៏ប្រសើររបស់ក្រុមជំនុំលោកអ្នក។ ចូរជ្រើសរើសយកបីដែលសំខាន់បំផុតពីក្នុងបញ្ជីនីមួយៗ ហើយសរសេរដាក់នៅត្រង់នេះ។

___

___

___

៦. ជាចុងក្រោយ ចូរសរសេរសេចក្តីថ្លែងការណ៍និមិត្តដែលប្រើពាក្យពណ៌នាដ៏សំខាន់បំផុត អ្នកទទួលបានការបម្រើ និងឃ្លាប្រាប់សកម្មភាព។ (លោកអ្នកអាចប្រើសេចក្តីថ្លែងការណ៍និមិត្តទីបី ឬទីបួនខាងលើធ្វើជាគំរូ)។

___

___

___

ចូរចែកចាយសេចក្តីថ្លែងការណ៍និមិត្តដែលលោកអ្នកបានសរសេរប្រាប់ក្រុមធំ។ ចូរធ្វើការរួមគ្នាជាមួយក្រុមធំ

ដើម្បីធានាថា លោកអ្នកជ្រើសរើសពាក្យបានច្បាស់ និងបង្ហាញប្រាប់គំនិតគិតរបស់លោកអ្នកយ៉ាងប្រាកដ។

៧. ចូរកត់ត្រាយោបល់ដែលបានចែកចាយ ហើយសរសេរសេចក្តីថ្លែងការណ៍និមិត្តចុងក្រោយនៅត្រង់នេះ។

___

___

___

៨. តើមានអត្ថបទព្រះគម្ពីរអ្វីខ្លះដែលគាំទ្រនិមិត្តនេះ?

___

___

___

៩. ចូរកែសម្រួលសេចក្តីថ្លែងការណ៍និមិត្ត ដើម្បីឲ្យច្បាស់លាស់ និងសាមញ្ញ។ តើលោកអ្នកអាចប្រាប់និមិត្តនេះដល់ក្រុមចាប់ផ្តើម ហើយអញ្ជើញពួកគេឲ្យទទួលយកនិមិត្តនេះធ្វើជានិមិត្តរបស់ខ្លួនបានយ៉ាងដូចម្តេច? តើក្រុមជំនុំត្រូវយល់ និងជឿអ្វី ដើម្បីគាំទ្រនិមិត្តនេះ? តើលោកអ្នកអាចជួយក្រុមជំនុំធ្វើកិច្ចការនេះបានយ៉ាងដូចម្តេច?

___

___

___

___

___

___

អាហារថ្ងៃត្រង់ (៦០ នាទី)

# ម៉ោងទី ៤
# ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: បេសកកម្ម (៦០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរប្រើមេរៀនខាងក្រោម ដើម្បីណែនាំអំពីគោលគំនិតដ៏ជាសេចក្តីថ្លែងការណ៍បេសកកម្ម។ ចូរដឹកនាំក្រុមនៅក្នុងការបំពេញសកម្មភាពដែលមានដូចខាងក្រោម។

## របៀបបង្កើតសេចក្តីថ្លែងការណ៍បេសកកម្ម
រំឭកឡើងវិញ & គោលគំនិតថ្មី (១៥ នាទី)

រំឭកឡើងវិញ
សេចក្តីថ្លែងការណ៍និមិត្តគឺជាការពណ៌នាដ៏ច្បាស់លាស់ និងជាក់លាក់អំពីអ្វីដែលលោកអ្នកជឿថា ព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំក្លាយជាអ្វី។ និមិត្ត គឺនិយាយអំពីក្រុមជំនុំនឹងធ្វើជានរណា។

គោលគំនិតថ្មី
សេចក្តីថ្លែងការណ៍បេសកកម្មសង្ខេបរបៀបដែលក្រុមជំនុំនឹងធ្វើឲ្យនិមិត្តក្លាយទៅជាការពិត។

សេចក្តីថ្លែងការណ៍បេសកកម្មប្រាប់សកម្មភាពដែលនឹងសម្រេចនិមិត្ត។

សេចក្តីថ្លែងការណ៍បេសកកម្ម និយាយអំពី សកម្មភាព។

ដើម្បីឲ្យពាក់ព័ន្ធនឹងតំបន់គោលដៅរបស់លោកអ្នក សេចក្តីថ្លែងការណ៍បេសកកម្មរបស់លោកអ្នកគួរតែឆ្លុះបញ្ចាំងឲ្យឃើញអ្វីដែលលោកអ្នករៀនបាននៅក្នុងការស្រាវជ្រាវរបស់លោកអ្នក។

I. បេសកកម្មរបស់ក្រុមជំនុំទីករស់គឺរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ តាមរយៈការថ្វាយបង្គំព្រះត្រីឯក ការប្រកាសព្រះបន្ទូល ការបម្រើដល់អ្នកជិតខាងយើង ការបង្រៀនអ្នកជឿចាប់តាំងពីកូនក្មេងរហូតដល់មនុស្សចាស់ និងការប្រកបគ្នាជាមួយគ្រួសាររបស់ព្រះ។

II. នៅក្រុមជំនុំសហគមន៍ជីវិតថ្មី យើងនឹងធ្វើជាពន្លឺរបស់ព្រះគ្រិស្តតាមរយៈ:

- ការថ្វាយបង្គំព្រះដ៏ពិតដោយវិញ្ញាណ និងសេចក្តីពិត (យ៉ូហាន ៤:២៤)។
- ប្រកាសព្រះបន្ទូលរបស់ព្រះយ៉ាងច្បាស់លាស់ ទាំងក្នុង និងក្រៅក្រុមជំនុំ (ម៉ាថាយ ២៨:១៨-២០)។
- បម្រើអ្នកជិតខាង និងគ្រួសាររបស់យើង អ្នកតូចទាប និងអ្នកដែលត្រូវបានគេបំភ្លេចចោលនៅក្នុងសហគមន៍របស់យើង ដោយសេចក្តីស្រឡាញ់របស់ព្រះគ្រិស្ត (ម៉ាកុស ១២:៣១)។
- រីកចម្រើនឡើងនៅក្នុងជំនឿ និងជួយអ្នកដទៃទៀតឲ្យរីកចម្រើនឡើងដែរ (២ ពេត្រុស ៣:១៨)។
- [illegible] នៅក្នុងព្រះគ្រិស្ត ដោយសេចក្តីស្រឡាញ់របស់ព្រះគ្រិស្ត (រ៉ូម ១២:១០, ១៣)។

និមិត្ត - បេសកកម្ម [illegible]

## សកម្មភាពផ្សេងៗ (៤៥ នាទី)

១. ដោយផ្អែកលើគំរូសេចក្តីថ្លែងការណ៍បេសកកម្មខាងលើ តើក្រុមជំនុំទាំងនេះនឹងធ្វើអ្វីខ្លះ?

___

___

___

២. ចម្លងសេចក្តីថ្លែងការណ៍និមិត្តរបស់ក្រុមជំនុំលោកអ្នកដាក់នៅខាងក្រោមនេះ (អ្វីដែលលោកអ្នកបានសរសេរនៅក្នុងសន្លឹកកិច្ចការ ១)។

___

___

៣. តើក្រុមជំនុំរបស់លោកអ្នកចង់ឈោងចាប់នរណា?

៤. តើក្រុមជំនុំរបស់លោកអ្នកនឹងសម្រេចនិមិត្តឈោងចាប់មនុស្សទាំងនេះបានយ៉ាងដូចម្តេច? តើលោកអ្នកនឹងធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យនិមិត្តនោះក្លាយទៅជាការពិត?ចូរធ្វើបញ្ជីសកម្មភាពដែលច្បាស់លាស់:

យើងផ្តល់យោបល់ឲ្យសេចក្តីថ្លែងការណ៍បេសកកម្មនីមួយៗដាក់បញ្ចូលតួនាទីសំខាន់ទាំងប្រាំរបស់ក្រុមជំនុំ:

- ការប្រកាស និងការផ្សាយដំណឹងល្អ
- ការអប់រំ និងការបង្កើតសិស្ស
- ការបម្រើ
- ការប្រកប
- ការថ្វាយបង្គំ

៥. សេចក្តីថ្លែងការណ៍បេសកកម្មគួរតែប្រាប់អំពីរបៀបដែលនិមិត្តនឹងបានសម្រេច។ ចូរធ្វើឲ្យប្រាកដថាបានដាក់បញ្ចូលរបៀបដែលការធ្វើសកម្មភាពនៅក្នុងសេចក្តីថ្លែងការណ៍បេសកកម្មនឹងសម្រេច (ដោយសារព្រះចេស្តារបស់ព្រះ) និមិត្ត។ ចូរកែលម្អសេចក្តីថ្លែងការណ៍បេសកកម្មរបស់លោកអ្នក ហើយសរសេរដាក់នៅត្រង់នេះ។

៦. តើមានអត្ថបទគម្ពីរអ្វីខ្លះដែលគាំទ្រសកម្មភាពកត់ត្រានៅក្នុងសេចក្តីថ្លែងការណ៍បេសកកម្មរបស់លោកអ្នក?

៧. ចូរចែកចាយសេចក្តីថ្លែងការណ៍និមិត្ត និងសេចក្តីថ្លែងការណ៍បេសកកម្មរបស់លោកអ្នក (រួមបញ្ចូលទាំងមូលដ្ឋានគ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់សេចក្តីថ្លែងការណ៍ទាំងនោះ) ប្រាប់ក្រុមធំ និងសរសេរដាក់នៅត្រង់នេះ។

# ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៤

ចូរចែកចាយនិមិត្ត និងបេសកកម្មរបស់លោកអ្នកប្រាប់ក្រុមជំនុំដែលគាំទ្រ និងគ្រូគង្វាលរបស់លោកអ្នក។

មុនពេលដែលត្រឡប់មករៀនម៉ូឌុល ៤ ចូរចែកចាយសេចក្តីថ្លែងការណ៍និមិត្ត និងសេចក្តីថ្លែងការណ៍បេសកកម្មរបស់លោកអ្នក (រួមបញ្ចូលទាំងមូលដ្ឋានគ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់សេចក្តីថ្លែងការណ៍ទាំងនោះ) ប្រាប់ក្រុមគាំទ្រ ក្រុមជំនុំមេ និងគ្រូឧបជ្ឈាររបស់លោកអ្នក។ លោកអ្នកប្រហែលជាចង់សុំគ្រូគង្វាលឲ្យអធិប្បាយមេរៀនភាគអំពីតួនាទីសំខាន់ (ភារកិច្ច) ទាំងប្រាំរបស់ក្រុមជំនុំ ដើម្បីរៀបចំក្រុមជំនុំឲ្យយល់ និងទទួលយកបេសកកម្មរបស់ខ្លួន។

នៅពេលដែលលោកអ្នកធ្វើបទបង្ហាញសេចក្តីថ្លែងការណ៍និមិត្ត និងសេចក្តីថ្លែងការណ៍បេសកកម្ម ចូរសួរថាតើសមាជិកឯកភាពជាមួយសេចក្តីទាំងនោះ និងត្រៀមខ្លួនដើម្បីគាំទ្រសេចក្តីទាំងនោះដែរឬយ៉ាងណា។ ចូរអញ្ជើញសមាជិកឲ្យប្តេជ្ញាចិត្តធ្វើការជាមួយគ្នាដើម្បីសម្រេចសេចក្តីថ្លែងការណ៍ទាំងនោះ។

ប្រសិនបើក្រុមគាំទ្ររបស់លោកអ្នក និងក្រុមជំនុំមេមិនឯកភាពចំពោះនិមិត្ត និងបេសកកម្ម ដូចដែលបានកំណត់ដោយអ្នកដឹកនាំ នោះពិបាកណាស់នៅក្នុងការធ្វើព័ន្ធកិច្ច និងធ្វើការផ្លាស់ប្តូរដែលចាំបាច់ដើម្បីសម្រេចនិមិត្តនោះតាមរយៈបេសកកម្ម។ អ្នកដាំក្រុមជំនុំ អ្នកដឹកនាំក្រុមជំនុំ និងក្រុមគាំទ្រត្រូវប្រឹងប្រែងធ្វើឲ្យមានការឯកភាពគ្នាអំពីនិមិត្ត និងបេសកកម្ម មុនពេលធ្វើការផ្លាស់ប្តូរដ៏សំខាន់ណាមួយ។

# ម៉ោងទី ៥
# ផែនការមេរៀនរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: គុណតម្លៃ (៦០ នាទី)

**ការណែនាំសម្រាប់អ្នកសម្របសម្រួល:** ចូរប្រើមេរៀនខាងក្រោម ដើម្បីណែនាំអំពីគោលគំនិតជំងសេចក្តីថ្លែងការណ៍គុណតម្លៃស្នូល។ ចូរដឹកនាំក្រុមនៅក្នុងការបំពេញសកម្មភាពដែលមានដូចខាងក្រោម។

## របៀបបង្កើតសេចក្តីថ្លែងការណ៍គុណតម្លៃស្នូល (១៥ នាទី)
រំឭកឡើងវិញ & គោលគំនិតថ្មី

រំឭកឡើងវិញ
និមិត្ត ពណ៌នាអំពីអ្វីដែលព្រះជាម្ចាស់ចង់ឲ្យលោកអ្នក**ធ្វើជាអ្វី**។
បេសកកម្ម ពណ៌នាអំពីអ្វីដែលព្រះជាម្ចាស់ចង់ឲ្យយើងធ្វើអ្វី។

គោលគំនិតថ្មី
គុណតម្លៃស្នូលពណ៌នាអំពីរបៀបដែលលោកអ្នកនឹងប្រកាន់ឥរិយាបថ នៅពេលដែលលោកអ្នកធ្វើបេសកកម្ម ដើម្បីសម្រេចនិមិត្ត។

## ឧទាហរណ៍ពីរអំពីសេចក្តីថ្លែងការណ៍គុណតម្លៃស្នូល:

១. គុណតម្លៃស្នូលរបស់ក្រុមជំនុំថ្មដានៃសេចក្តីសង្គ្រោះ (បង្ហាញប្រាប់នៅក្នុងកិរិយាស័ព្ទ)
ក្នុងនាមជាប្រជារាស្ត្ររបស់ព្រះ យើងប្តេជ្ញាចិត្ត:

- បានត្រឡប់ដូចជារូបអង្គរបស់ព្រះគ្រិស្ត ទាំងបុគ្គល ទាំងក្រុមជំនុំ (រ៉ូម ៨:២៩, ២ កូរិនថូស ៣:១៨)។
- និយាយសេចក្តីពិតដោយសេចក្តីស្រឡាញ់ (អេភេសូរ ៤:១៥,២៥,២៩) នៅក្នុងការកែតម្រង់ និងការដាស់តឿន និងដោយមានតម្លាភាពអំពីការសម្រេចចិត្ត និងបញ្ហាហិរញ្ញវត្ថុ។
- បម្រើគ្នាទៅវិញទៅមកនៅក្នុងសេចក្តីស្រឡាញ់ ដោយស្គាល់អំណោយទានរបស់មនុស្សគ្រប់គ្នា និងផ្តល់ឲ្យពួកគេមានឱកាសប្រើអំណោយទានរបស់ខ្លួន (រ៉ូម ១២:១-៨, ១ ពេត្រុស ៤:១០-១១) និងបង្រៀនមនុស្សគ្រប់វ័យគ្រប់សមត្ថភាពទាំងអស់ (ចោទិយកថា ៦:២០ និង ១១:១៨-២១ ម៉ាថាយ ២៨:១៨-២០)។

២. គុណតម្លៃស្នូលរបស់ក្រុមជំនុំទឹករស់ (បង្ហាញប្រាប់នៅក្នុងនាម និងកិរិយាស័ព្ទ)
ក្នុងនាមជាសហគមន៍គ្រិស្តបរិស័ទ យើងឲ្យតម្លៃ:

ធ្វើជា - ធ្វើ - របៀប - ប្រកាន់ឥរិយាបថ
- ការប្រកាសព្រះបន្ទូលព្រះដោយច្បាស់លាស់ និងដោយពាក់ព័ន្ធ (ម៉ាថាយ ២៨:១៨-២០, ២ ធីម៉ូថេ ៤:២)។
- ការថ្វាយបង្គំផ្តោតលើព្រះត្រីឯក មិនមែនផ្តោតលើចំណង់ចំណូលចិត្តរបស់យើងទេ (ចោទិយកថា ៥:៦-១០)។
- ការបម្រើដល់អ្នកខ្វះខាតទាំងនៅក្នុង និងក្រៅក្រុមជំនុំ (ម៉ាកុស ១២:៣១ អេភេសូរ ៥:១-២)។
- ការបង្កើតសិស្សសម្រាប់មនុស្សចាប់តាំងពីកុមារដល់មនុស្សចាស់ (ម៉ាថាយ ២៨:១៨-២០ ចោទិយកថា ៦:២០ និង ១១:១៨-២១)។
- ការស្គាល់ និងការមើលថែបងប្អូនប្រុសស្រីរបស់យើងនៅក្នុងព្រះគ្រិស្ត (អេភេសូរ ៤:២, ២៥-៣២)។
- អ្នកដឹកនាំជាអ្នកបម្រើ និងសមាជិកដែលប្រើអំណោយទានរបស់ខ្លួន (ម៉ាថាយ ២០:២៥-២៨, ១ ពេត្រុស ៤:១០-១១)។
- តួនាទីជាអ្នកមើលការខុសត្រូវលើធនធានប្រកបដោយការទទួលខុសត្រូវ (ទំនុកតម្កើង ២៤:១)។

ធម្មតា សេចក្តីថ្លែងការណ៍គុណតម្លៃស្នូលដាក់បញ្ចូលគុណតម្លៃ ៣-៧។ សេចក្តីថ្លែងការណ៍គុណតម្លៃគួរតែខ្លីល្មមដែលងាយស្រួលចាំ។

ជាញឹកញាប់ សកម្មភាពដែលត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍គុណតម្លៃស្នូល ត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍បេសកកម្ម។ ការខុសប្លែកគ្នាគឺថា នៅក្នុងសេចក្តីថ្លែងការណ៍គុណតម្លៃស្នូល សកម្មភាពទាំងនេះត្រូវបានបង្ហាញថាជាលទ្ធផលកើតចេញពីលក្ខណៈជាក់លាក់របស់អត្តចរិត។ ឧទាហរណ៍ គុណតម្លៃស្នូលរបស់ក្រុមជំនុំទឹករស់លើកឡើងមិនត្រឹមតែ «ការថ្វាយបង្គំ»ប៉ុណ្ណោះទេ ថែមទាំងប្រភេទនៃការថ្វាយបង្គំដែល

សំខាន់ទៀតផង: ការថ្វាយបង្គំផ្តោតលើព្រះជាម្ចាស់ មិនមែនលើចំណង់ចំណូលចិត្តរបស់មនុស្សទេ ដែលបង្ហាញប្រាប់អត្តចរិតសុចរិត។ គុណតម្លៃស្នូលធ្វើជាការរំពឹងទុកជាមូលដ្ឋានគ្រឹះរបស់ក្រុមជំនុំដែលអ្នកដឹកនាំនឹងពិចារណា នៅពេលដែលធ្វើការសម្រេចចិត្ត វាយតម្លៃអ្នកដឹកនាំ បម្រើដល់សមាជិក។ល។

គុណតម្លៃស្នូលទាំងអស់គួរតែមានមូលដ្ឋានគ្រឹះនៅក្នុងព្រះគម្ពីរ។ គុណតម្លៃត្រូវតែមានការគាំទ្រពីអត្ថបទគម្ពីរ ឬគោលការណ៍ដែលបានបង្រៀននៅក្នុងបទគម្ពីរ។

យើងផ្តល់យោបល់ឲ្យរៀបចំគុណតម្លៃរបស់លោកអ្នកទៅតាមលំដាប់លំដោយអាទិភាព។ ជាញឹកញាប់ ការដឹកនាំប្រកបដោយប្រសិទ្ធភាពតម្រូវឲ្យមនុស្ស ឬក្រុមជំនុំធ្វើការវិនិច្ឆ័យរវាងគុណតម្លៃដែលប្រកួតប្រជែងគ្នា។ ការរៀបគុណតម្លៃរបស់លោកអ្នកតាមលំដាប់លំដោយអាទិភាពជួយដឹកនាំការសម្រេចចិត្តប្រភេទនោះ។ ឧទាហរណ៍ ប្រសិនបើការសម្រេចចិត្ត ឬសកម្មភាពដែលគាំទ្រគុណតម្លៃ # ៥ តម្រូវឲ្យសម្របសម្រួលគុណតម្លៃ # ១ គុណតម្លៃដែលបានរៀបតាមអាទិភាពនឹងបង្ហាញប្រាប់ថា ការសម្រេចចិត្ត និងសកម្មភាពដែលគាំទ្រគុណតម្លៃ # ៥ ត្រូវកែសម្រួលឡើងវិញ (ឬនៅក្នុងករណីខ្លះ បោះបង់ចោល) ដើម្បីឲ្យក្រុមជំនុំនៅតែស្មោះត្រង់ចំពោះគុណតម្លៃដែលសំខាន់ជាងគេបំផុតរបស់ខ្លួន។

## ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៤

ការកំណត់គុណតម្លៃរបស់ក្រុមជំនុំថ្មីដែលបានដាំ (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរអានសេចក្តីណែនាំសម្រាប់លំហាត់ ហើយឆ្លើយរាល់សំណួរដែលសិក្ខាកាមមាន។

១. ចូរធ្វើការរួមគ្នាជាមួយគ្រូគង្វាលរបស់លោកអ្នក អ្នកដឹកនាំមកពីក្រុមជំនុំដែលឧបត្ថម្ភលោកអ្នក និងសមាជិករបស់ក្រុមជំនុំថ្មីដែលបានដាំ (ប្រសិនបើលោកអ្នកមានសមាជិករួចហើយ) ដើម្បីបង្កើតសេចក្តីថ្លែងការណ៍គុណតម្លៃស្នូល។ យើងផ្តល់យោបល់ឲ្យមានក្រុមដែលមានគ្នា ៥ ទៅ ៩ នាក់។ ចូរចែកសិក្ខាកាមជាក្រុមដែលមានគ្នាបី ឬបួននាក់។ នៅក្នុងក្រុមនីមួយៗ:

- ចូរអាន និមិត្ត និងបេសកកម្មម្តងទៀត។
- ចូរអានឡើងវិញឧទាហរណ៍ទាំងពីរអំពីគុណតម្លៃស្នូល។ ឧទាហរណ៍ទាំងនោះប្រហែលជាផ្តល់ការដឹកនាំនៅពេលដែលលោកអ្នកគិតអំពីគុណតម្លៃស្នូលសម្រាប់ក្រុមជំនុំរបស់លោកអ្នក។
- ចូរកំណត់អត្តសញ្ញាណគុណតម្លៃសំខាន់ៗដែលមានការគាំទ្រនៅក្នុងព្រះគម្ពីរ ដែលឆ្លុះបញ្ចាំងអំពីរបៀបដែលលោកអ្នកចង់ប្រព្រឹត្តក្នុងនាមជាក្រុមជំនុំ (ត្រូវសង្កត់ធ្ងន់លើគុណតម្លៃនៅក្នុងបរិបទវប្បធម៌របស់ក្រុមជំនុំលោកអ្នក ជាជាងគុណតម្លៃនៅក្នុងឧទាហរណ៍សេចក្តីថ្លែងការណ៍ខាងលើ)។
- ចូរជ្រើសរើសគុណតម្លៃស្នូល ៥-៧ ដែលបង្ហាញប្រាប់របៀបដែលក្រុមជំនុំរបស់លោកអ្នក និងអ្នកដឹកនាំក្រុមជំនុំគួរតែប្រព្រឹត្តនៅក្នុងឆ្នាំខាងមុខ។ មានគុណតម្លៃជាច្រើនដែលអាចត្រូវបានកំណត់អត្តសញ្ញាណឡើង—លោកអ្នកត្រូវជ្រើសរើសគុណតម្លៃដែលសំខាន់បំផុតសម្រាប់ក្រុមជំនុំរបស់លោកអ្នកនៅពេលឥឡូវនេះ គឺជាគុណតម្លៃដែលនឹងដឹកនាំ និងគាំទ្រ និមិត្ត និងបេសកកម្មរបស់លោកអ្នក។

២. ចូរសុំក្រុមនីមួយៗឲ្យធ្វើបទបង្ហាញបញ្ជីគុណតម្លៃស្នូលរបស់ខ្លួន។ ចូរកំណត់អត្តសញ្ញាណមូលដ្ឋានគ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់គុណតម្លៃនីមួយៗ។

៣. ចូរកំណត់អត្តសញ្ញាណគុណតម្លៃស្នូល ៥-៧ ជាមួយគ្នា ដែលបង្ហាញប្រាប់របៀបដែលព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំរបស់លោកអ្នកប្រព្រឹត្តនៅក្នុងអំឡុងពេល ៣ ទៅ ៥ ឆ្នាំក្រោយ។

៤. ចូរធ្វើបទបង្ហាញបញ្ជីគុណតម្លៃស្នូលប្រាប់ក្រុមជំនុំរបស់លោកអ្នក រួមជាមួយមូលដ្ឋានគ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់គុណតម្លៃទាំងនោះ ដោយពន្យល់អំពីមូលហេតុដែលលោកអ្នកបានជ្រើសរើសគុណតម្លៃនីមួយៗ។ ចូរសុំមតិយោបល់ពីសមាជិក។ ចូរកែសម្រួលបញ្ជីគុណតម្លៃឡើងវិញ ប្រសិនបើចាំបាច់ ប៉ុន្តែត្រូវប្រាកដជានិច្ចថា គុណតម្លៃស្នូលទាំងនោះមានមូលដ្ឋានគ្រឹះនៅលើព្រះបន្ទូលរបស់ព្រះ។

៧. ចូរផ្តល់ឱកាស (ឧទាហរណ៍ កម្មវិធីប្តេជ្ញាចិត្តពិសេស) ឲ្យសមាជិកក្រុមជំនុំទាំងអស់ប្តេជ្ញាចិត្តរស់នៅស្រប

តាមគុណតម្លៃស្នូលទាំងនេះ។

៨. ចូរត្រៀមខ្លួនដើម្បីចែកចាយសេចក្ដីថ្លែងការណ៍គុណតម្លៃរបស់លោកអ្នកនៅក្នុងអំឡុងពេលសិក្សាម៉ូឌុល ៤។ ចូរត្រៀមខ្លួនដើម្បីពិភាក្សាអំពីដំណើរការដែលលោកអ្នកបានចូលរួមដើម្បីបង្កើតសេចក្ដីថ្លែងការណ៍គុណតម្លៃស្នូលនេះ។

ចូរសរសេរសេចក្ដីថ្លែងការណ៍គុណតម្លៃស្នូលរបស់លោកអ្នកនៅត្រង់នេះ:

________________________________________
________________________________________
________________________________________
________________________________________
________________________________________
________________________________________
________________________________________
________________________________________

សម្រាក (១៥ នាទី)

# ម៉ោងទី ៦
# ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: យុទ្ធសាស្រ្ត (៦០ នាទី)

## រំឭកឡើងវិញ & គោលគំនិតថ្មី (១៥ នាទី)

រំឭកឡើងវិញ
និមិត្ត ពណ៌នាអំពីអ្វីដែលព្រះជាម្ចាស់ចង់ឲ្យលោកអ្នកធ្វើជាអ្វី។
បេសកកម្ម ពណ៌នាអំពីអ្វីដែលព្រះជាម្ចាស់ចង់ឲ្យយើងធ្វើអ្វី។
គុណតម្លៃស្នូល ពណ៌នាអំពីអ្វីដែលព្រះជាម្ចាស់ចង់ឲ្យយើងប្រកាន់ឥរិយាបថ។

គោលគំនិតថ្មី
យុទ្ធសាស្រ្តគឺជាបញ្ជីសកម្មភាពជាក់លាក់ដែលលោកអ្នកនឹងធ្វើ ដើម្បីសម្រេចនិមិត្ត និងបេសកកម្មរបស់លោកអ្នក ខណៈពេលដែលកំពុងរស់នៅតាមគុណតម្លៃស្នូលរបស់លោកអ្នក។

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា: «នៅក្នុងម៉ូឌុល ១ លោកអ្នកត្រូវបានណែនាំឲ្យស្គាល់ជំហានទាំងប្រាំនៅក្នុងការដាំក្រុមជំនុំ និងវដ្តនៃការដាំក្រុមជំនុំ»។

ចូរដឹកនាំការរំឭកមេរៀនម៉ូឌុល ១ ឡើងវិញដែលនិយាយអំពីជំហានទាំងប្រាំនៅក្នុងការដាំក្រុមជំនុំ និងវដ្តនៃការដាំក្រុមជំនុំ។

ចូរនិយាយថា: «គ្រោងខាងក្រោមដាក់បញ្ចូលគោលគំនិតទាំងពីរនេះ ដើម្បីផ្តល់គ្រោងជាមូលដ្ឋានគ្រឹះមួយសម្រាប់យុទ្ធសាស្រ្តដាំក្រុមជំនុំ។ លំហាត់របស់លោកអ្នកគឺកំណត់ និងសរសេរសកម្មភាពជាក់លាក់ ៣ ទៅ ៥ ដែលលោកអ្នកនឹងចាត់ឡើងសម្រាប់ធាតុយុទ្ធសាស្រ្តនីមួយៗ។ ដូចដែលបានកត់សម្គាល់សម្រាប់ និមិត្ត និងបេសកកម្មរួចហើយ យុទ្ធសាស្រ្តរបស់លោកអ្នកគួរតែឆ្លុះបញ្ចាំងពីអ្វីដែលលោកអ្នករៀនបាននៅក្នុងការស្រាវជ្រាវរបស់លោកអ្នក»។

ចូរកំណត់ និងសរសេរសកម្មភាពជាក់លាក់ ៣ ទៅ ៥ ដែលលោកអ្នកនឹងចាត់ឡើងសម្រាប់ធាតុយុទ្ធសាស្រ្តនីមួយៗ។ យុទ្ធសាស្រ្តរបស់លោកអ្នក គួរតែឆ្លុះបញ្ចាំងពីអ្វីដែលលោកអ្នករៀនបាននៅក្នុងការស្រាវជ្រាវរបស់លោកអ្នក។

ធ្វើជា – ធ្វើ – ប្រកាន់ឥរិយាបថ – សកម្មភាពជាក់លាក់

## ការបង្កើតយុទ្ធសាស្រ្តដាំក្រុមជំនុំ (៤៥ នាទី)

### យុទ្ធសាស្រ្តរបស់ខ្ញុំក្នុងការដាំក្រុមជំនុំ

ក. ការអធិស្ឋាន
១. ______________________________
២. ______________________________
៣. ______________________________
៤. ______________________________
៥. ______________________________

ខ. ការផ្សាយដំណឹងល្អ
១. ______________________________

២. ____________________
៣. ____________________
៤. ____________________
៥. ____________________

គ. ការបង្កើតសិស្ស
១. ____________________
២. ____________________
៣. ____________________
៤. ____________________
៥. ____________________

ឃ. ការប្រកប (ការជួបជុំគ្នា)
១. ____________________
២. ____________________
៣. ____________________
៤. ____________________
៥. ____________________

ង. ការអភិវឌ្ឍន៍អ្នកដឹកនាំ
១. ____________________
២. ____________________
៣. ____________________
៤. ____________________
៥. ____________________

ច. ការថ្វាយបង្គំ
១. ____________________
២. ____________________
៣. ____________________
៤. ____________________
៥. ____________________

ឆ. ការបម្រើ
១. ____________________
២. ____________________
៣. ____________________
៤. ____________________
៥. ____________________

ជ. ការរីកចម្រើនឡើងជាពហុគុណ (បេសកកម្ម)
១. ____________________
២. ____________________
៣. ____________________

៤. ______________________________________________
៥. ______________________________________________

# ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៤

ចូរកែលម្អយុទ្ធសាស្ត្ររបស់លោកអ្នកនៅក្នុងការដាំក្រុមជំនុំ

នៅពេលដែលលោកអ្នករំឭកឡើងវិញ និងបង្កើតសេចក្តីថ្លែងការណ៍និមិត្ត សេចក្តីថ្លែងការណ៍បេសកកម្ម និងសេចក្តីថ្លែងការណ៍គុណតម្លៃស្នូលរបស់លោកអ្នកជាមួយគ្រូគង្វាល និងក្រុមគាំទ្ររបស់លោកអ្នក ចូរចែកចាយ និងកែសម្រួលយុទ្ធសាស្ត្ររបស់លោកអ្នកនៅក្នុងដំណើរការនេះផងដែរ។

# ការបញ្ចប់

តើបន្ទាប់ទៀតគឺជាអ្វី?

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូររំឭកឡើងវិញផែនការសកម្មភាពទាំងបីសម្រាប់ម៉ូឌុល ៤ (សូមមើលម៉ោងទី ៧ ៨ និង ៩ នៅក្នុងសៀវភៅនេះ)។ ចូរឆ្លើយរាល់សំណួរពាក់ព័ន្ធនឹងផែនការសកម្មភាពទាំងនោះ។
- ចូរសុំអ្នកស្ម័គ្រចិត្តឲ្យប្រាប់ចម្លើយរបស់ពួកគេសម្រាប់សំណួរខាងក្រោមតាមពាក្យរបស់ខ្លួន:

    ១. តើសេចក្តីថ្លែងការណ៍និមិត្ត ជាអ្វី? (សូមមើលម៉ោងទី ៣)
    ២. តើសេចក្តីថ្លែងការណ៍បេសកកម្ម ជាអ្វី? (សូមមើលម៉ោងទី ៤)
    ៣. តើសេចក្តីថ្លែងការណ៍គុណតម្លៃស្នូល ជាអ្វី? (សូមមើលម៉ោងទី ៥)
    ៤. តើយុទ្ធសាស្ត្រដាំក្រុមជំនុំ ជាអ្វី? (សូមមើលម៉ោងទី ៦)

- ចូរសុំសិក្ខាកាមឲ្យចែកចាយសេចក្តីដែលពួកគេរៀនបាននៅក្នុងការហ្វឹកហ្វឺននេះ ដែលធ្វើឲ្យពួកគេរំភើបចិត្ត និងលើកទឹកចិត្តពួកគេសម្រាប់ការងាររបស់ពួកគេក្នុងនាមជាអ្នកដាំក្រុមជំនុំ។
- ចូរឲ្យសិក្ខាកាមម្នាក់ៗសម្រេចចិត្តអំពីគោលដៅដាំក្រុមជំនុំរបស់ពួកគេសម្រាប់ខែនេះ។
- ចូរច្រៀងចម្រៀងថ្វាយបង្គំមួយបទជាមួយគ្នា ហើយបញ្ចប់ដោយការអធិស្ឋានសុំព្រះសម្រាប់អ្នកដាំក្រុមជំនុំទាំងនេះ។

ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៤: បញ្ជីត្រួតពិនិត្យ

- ➢ ចូរបង្កើត និងចែកចាយសេចក្តីថ្លែងការណ៍និមិត្ត និងសេចក្តីថ្លែងការណ៍បេសកកម្ម (សូមមើលម៉ោងទី ៣ និងទី ៤)
- ➢ ចូរបង្កើត និងចែកចាយសេចក្តីថ្លែងការណ៍គុណតម្លៃ (សូមមើលម៉ោងទី ៥)។
- ➢ ចូរចែកចាយ និងកែសម្រួលយុទ្ធសាស្ត្ររបស់លោកអ្នកនៅក្នុងការដាំក្រុមជំនុំ (សូមមើលម៉ោងទី ៦)។
- ➢ ចូរខំប្រឹងប្រែងធ្វើការឆ្ពោះទៅរកគោលដៅដាំក្រុមជំនុំរបស់លោកអ្នកសម្រាប់ខែនេះ (សូមមើលការបញ្ចប់)។

| គោលដៅដាំក្រុមជំនុំសម្រាប់ខែនេះ | |
|---|---|
| បុគ្គល | |
| អ្នកថ្មីដែលបានទាក់ទង | |
| អ្នកជឿថ្មី | |
| អ្នកថ្មីដែលបានទទួលពិធីជ្រមុជទឹក | |
| អ្នកដឹកនាំថ្មីកំពុងទទួលការហ្វឹកហ្វឺន | |

| ក្រុមតូច | |
|---|---|
| ក្រុមតូចថ្មី | |
| អ្នកចូលរួមថ្មីនៅក្នុងក្រុម | |
| អ្នកដឹកនាំថ្មីដែលមានក្រុមតូចមួយ | |

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ប្រសិនបើលោកអ្នកសល់ពេល ដោយព្រោះម៉ោងទី ៥ ក្នុងការបណ្តុះបណ្តាលនេះ មិនត្រូវការពេល ៦០ នាទីទេ លោកអ្នកអាចប្រើពេលនៅសល់តាមដែលត្រូវការ ឧទាហរណ៍ សម្រាប់រំឭកមេរៀនចាស់ ការបង្រៀនកាលពីមុន ការអធិស្ឋានជាក្រុមតូច ការឆ្លើយសំណួរ និងបញ្ហាប្រឈមដែលសិក្ខាកាមមាន ឬអាចសម្រាក មុនម៉ោងក៏បាន។